KB PRASAC Bank

ធនាគារ ខេប៊ីប្រាសាក់ ម.ក

លក្ខខណ្ឌនៃការប្រើប្រាស់
សេវាខេប៊ីប្រាសាក់ពាណិជ្ជករ

Terms and Conditions of Using KB PRASAC Merchant

ចោះពុម្ពលើកទី ២

មាតិកា

1. សេចក្តីផ្តើម....1
2. និយមន័យនៃពាក្យគន្លឹះ....1
3. ប្រភេទមុខងារសំខាន់ៗនៃសេវាខេប៊ីប្រាសាក់ពាណិជ្ជករ....4
4. ការចុះឈ្មោះប្រើប្រាស់សេវាខេប៊ីប្រាសាក់ពាណិជ្ជករ....4
5. ការស្នើសុំ និងទទួលខេអេចឃ្យូអរកូត និងសម្ភារៈពាក់ព័ន្ធ....6
6. ការទូទាត់ទំនិញ/សេវាកម្ម....6
7. ប្រតិបត្តិការទូទាត់ពីខេប៊ីប្រាសាក់....6
8. ការផ្ទៀងផ្ទាត់ប្រតិបត្តិការ....7
9. ម៉ោងប្រតិបត្តិការ....7
10. រូបិយប័ណ្ណ និងអត្រាប្តូរប្រាក់....7
11. ទំហំកំណត់នៃប្រតិបត្តិការ និងកម្រៃសេវា....7
12. សារជូនដំណឹង....8
13. លក្ខណៈផ្សេងៗសម្រាប់ការប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ពាណិជ្ជករ....8
14. ការបញ្ឈប់ការប្រើប្រាស់សេវាខេប៊ីប្រាសាក់ពាណិជ្ជករ....8
15. ការប្តូរប្រភេទគណនី....8
16. សុវត្ថិភាពលើការប្រើប្រាស់សេវាខេប៊ីប្រាសាក់ពាណិជ្ជករ....8
17. សិទ្ធិ និងកាតព្វកិច្ចរបស់លោក-លោកស្រី....10
18. សិទ្ធិ និងកាតព្វកិច្ចរបស់ខេប៊ីប្រាសាក់....12
19. ការកែប្រែកម្រៃសេវា ទំហំកំណត់ លក្ខខណ្ឌផ្សេងៗ និងការជូនដំណឹង....13
20. ការទប់ស្កាត់ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម....14
21. ច្បាប់ និងការដោះស្រាយវិវាទ....14
22. ស្វ័យភាព នៃបញ្ញត្តិ....14
23. ភាសា....14

1. សេចក្តីផ្តើម

1.1. លក្ខខណ្ឌនៃការប្រើប្រាស់សេវាខេប៊ីប្រាសាក់ពាណិជ្ជករ តទៅហៅថា **«លក្ខខណ្ឌប្រើប្រាស់»** គឺជាកិច្ចព្រមព្រៀងរវាង **លោក-លោកស្រី** ជាមួយ ធនាគារ ខេប៊ីប្រាសាក់ ម.ក តទៅហៅថា **«ខេប៊ីប្រាសាក់»** ទាក់ទងទៅនឹងការប្រើប្រាស់សេវាខេប៊ីប្រាសាក់ពាណិជ្ជករ និងការធ្វើជាពាណិជ្ជកររបស់ខេប៊ីប្រាសាក់។

1.2. សូម លោក-លោកស្រី អាន **លក្ខខណ្ឌប្រើប្រាស់** នេះដោយប្រុងប្រយ័ត្ន មុននឹងចុច **«យល់ព្រម»** ដើម្បីបន្តការចុះឈ្មោះប្រើប្រាស់សេវាខេប៊ីប្រាសាក់ពាណិជ្ជករ។

1.3. នៅពេលលោក-លោកស្រីបានចុច **«យល់ព្រម»** មានន័យថាលោក-លោកស្រីបានអាន បានយល់ និងព្រមអនុវត្តនូវគ្រប់លក្ខខណ្ឌ ដែលបានចែងនៅក្នុងលក្ខខណ្ឌប្រើប្រាស់នេះ ព្រមទាំងលក្ខខណ្ឌទូទៅនៃការប្រើប្រាស់ផលិតផល និងសេវាកម្ម របស់ធនាគារ ខេប៊ីប្រាសាក់ ហើយ លោក-លោកស្រី យល់ព្រមទទួលខុសត្រូវលើការប្រើប្រាស់សេវាខេប៊ីប្រាសាក់ពាណិជ្ជករ និងយល់ព្រមធ្វើជាពាណិជ្ជកររបស់ខេប៊ីប្រាសាក់។

1.4. លក្ខខណ្ឌ នៃ ការប្រើប្រាស់នេះមានប្រសិទ្ធភាពចាប់ពីពេល ដែលកម្មវិធីខេប៊ីប្រាសាក់ពាណិជ្ជករ ត្រូវបានដំឡើងនៅលើទូរស័ព្ទរបស់លោក-លោកស្រី រហូតដល់ពេលលុបកម្មវិធីនេះចេញ ឬ រហូតដល់លោក-លោកស្រី ធ្វើការស្នើសុំបញ្ឈប់ការប្រើប្រាស់ជាលាយលក្ខណ៍អក្សរ។

1.5. លក្ខខណ្ឌ នៃ ការប្រើប្រាស់នេះអនុញ្ញាតឱ្យ លោក-លោកស្រី អាចប្រើប្រាស់សេវាខេប៊ីប្រាសាក់ពាណិជ្ជករ នៅក្នុងមធ្យោបាយ និងសម្រាប់គោលបំណងដូចខាងក្រោម៖

ក) ដោនឡូដ និងដំឡើងកម្មវិធីខេប៊ីប្រាសាក់ពាណិជ្ជករ លើទូរស័ព្ទដៃ

ខ) ទទួលការទូទាត់ដោយការបង្ហាញ និងស្កេនខេអេចឃ្យូអរកូតតាមរយៈទូរស័ព្ទដៃរបស់ លោក-លោកស្រី ឬ ស្កេនខេអេចឃ្យូអរកូត ជាជើងបញ្ជរ ខ្សែកាត ដែលបានផ្តល់ដោយខេប៊ីប្រាសាក់ ឬ មធ្យោបាយទូទាត់មិនប្រើសាច់ប្រាក់ផ្សេងៗទៀត ដែលបង្កលក្ខណៈងាយស្រួល សុវត្ថិភាព និងទំនើបទាន់សម័យ។

1.6. វិសាលភាពនៃលក្ខខណ្ឌ និង ការប្រើប្រាស់នេះត្រូវរួមបញ្ចូលទាំងការធ្វើបច្ចុប្បន្នភាពបន្តបន្ទាប់ និងកំណែថ្មីទាំងអស់ របស់សេវាខេប៊ីប្រាសាក់ពាណិជ្ជករ។ តាមរយៈការយល់ព្រមដំឡើងបច្ចុប្បន្នភាព ឬ កំណែថ្មីៗរបស់កម្មវិធីនេះ លោក-លោកស្រី យល់ព្រមទទួលយកលក្ខខណ្ឌនេះសម្រាប់បច្ចុប្បន្នភាព និងកំណែថ្មីៗ ដែលពាក់ព័ន្ធ។

2. និយមន័យនៃពាក្យគន្លឹះ

- **ពាក្យ «លោក-លោកស្រី»** ៖ សំដៅដល់អតិថិជនជា ម្ចាស់គណនី ឬ ជាម្ចាស់អាជីវកម្ម ដែលបានចុះឈ្មោះប្រើប្រាស់សេវាខេប៊ីប្រាសាក់ពាណិជ្ជករ។
- **កិច្ចព្រមព្រៀង** ៖ សំដៅដល់កិច្ចសន្យាស្របច្បាប់ និងចងកាតព្វកិច្ចរវាង លោក-លោកស្រី និង ធនាគារ ខេប៊ីប្រាសាក់ ម.ក។ កិច្ចព្រមព្រៀងនេះកំណត់នូវការប្រើប្រាស់សេវាខេប៊ីប្រាសាក់ពាណិជ្ជករ សម្រាប់លោក-លោកស្រី ដែលបានចុះឈ្មោះប្រើប្រាស់។

- **សេវាខេប៊ីប្រាសាក់ពាណិជ្ជករ** ៖ គឺជាសេវា ដែលខេប៊ីប្រាសាក់ផ្តល់ជូនអាជីវករ និងពាណិជ្ជករ ដើម្បីសម្រួលដល់អាជីវកម្មរបស់គាត់ ជាពិសេសលើមធ្យោបាយទូទាត់តាមរយៈការស្កេនខេអេចឃ្យូអរកូត (KHQR Code)។
- **កម្មវិធីខេប៊ីប្រាសាក់ពាណិជ្ជករ** ៖ គឺជាកម្មវិធីមួយដែលអនុញ្ញាតឱ្យអតិថិជនអាចទាញយកកម្មវិធីពី App Store/Play Store នៅក្នុងទូរស័ព្ទដៃឆ្លាតវៃ និងអាចធ្វើការចុះឈ្មោះធ្វើជាពាណិជ្ជកររបស់ខេប៊ីប្រាសាក់បានដោយខ្លួនឯង និងអាចធ្វើការគ្រប់គ្រងអាជីវកម្មរបស់ខ្លួនលើកម្មវិធី បានយ៉ាងងាយស្រួល មានប្រសិទ្ធភាពខ្ពស់ និងគ្រប់ពេលវេលា។
- **ម្ចាស់អាជីវកម្ម (Merchant)** ៖ គឺសំដៅលើអាជីវករ ដែលប្រកបអាជីវកម្មលក់ផលិតផល ឬ សេវាកម្មផ្សេងៗ។
- **សហពាណិជ្ជករ (Co-Merchant)** ៖ សំដៅលើដៃគូសហការ ឬ ជាម្ចាស់អាជីវកម្មរួមគ្នា នៃហាងលក់ទំនិញ ឬ ដេប៉ូ បោះដុំ ឬ លក់រាយ ឬ ភោជនីយដ្ឋាន ឬ សណ្ឋាគារ ...ដែលម្ចាស់អាជីវកម្មនោះមានគណនីនៅខេប៊ីប្រាសាក់ និងបានចុះឈ្មោះប្រើប្រាស់សេវាខេប៊ីប្រាសាក់ពាណិជ្ជករ ដើម្បីត្រួតពិនិត្យរបាយការណ៍ និងទទួលការទូទាត់។
- **អ្នកគ្រប់គ្រងហាង (Supervisor)** ៖ សំដៅលើបុគ្គលិក ដែលម្ចាស់អាជីវកម្ម បានជួលមកគ្រប់គ្រងហាងទំនិញ ឬ សេវាកម្ម... ហើយត្រូវបានម្ចាស់អាជីវកម្មអនុញ្ញាតឱ្យចុះឈ្មោះប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ពាណិជ្ជករ ក្នុងសិទ្ធិជា អ្នកគ្រប់គ្រងហាង (Supervisor)។
- **អ្នកគិតលុយ (Cashier)** ៖ សំដៅលើបុគ្គលិក ដែលម្ចាស់អាជីវកម្ម បានជួលមកដើម្បីទទួលការទូទាត់ថ្លៃទំនិញ ឬ សេវា នៅក្នុងហាងលក់ទំនិញ ឬ សេវាកម្ម... ហើយត្រូវបានម្ចាស់អាជីវកម្មអនុញ្ញាតឱ្យចុះឈ្មោះប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ពាណិជ្ជករ ក្នុងសិទ្ធិជា អ្នកគិតលុយ (Cashier)។
- **បញ្ជរ (Counter)** ៖ គឺជាកន្លែងទូទាត់ថ្លៃទំនិញ ឬ សេវាកម្ម ដែលអតិថិជនបានទិញ ឬ ប្រើប្រាស់សេវា ដែលអាចទូទាត់ជាសាច់ប្រាក់ ឬ ស្កេនទូទាត់ជាមួយខេអេចឃ្យូអរកូត។
- **ខេអេចឃ្យូអរកូត (KHQR Code)** ៖ ជាខេអេចឃ្យូអរកូត ដែលតំណាងឱ្យលេខគណនីរបស់ លោក-លោកស្រី ឬ ភាគីផ្សេងទៀត ប្រើប្រាស់សម្រាប់ទទួលប្រាក់ ឬ ទូទាត់ថ្លៃទំនិញ/សេវាកម្មតាមរយៈមុខងារស្កេនខេអេចឃ្យូអរកូត។
- **គណនី** ៖ សំដៅលើគណនីប្រាក់បញ្ញើសន្សំទាំងឡាយណាដែល លោក-លោកស្រីបានបើកជាមួយ ខេប៊ីប្រាសាក់ អាចជា៖ គណនីសន្សំពាណិជ្ជករ ឬ គណនីសន្សំ ឬ គណនីចម្រើនគ្មានកាលកំណត់ ឬ គណនីចម្រើនតាមលំដាប់ ឬ គណនីចរន្ត ឬ គណនីចរន្តព្រីមៀម។ល។
- **គណនីឯកត្តជន** ៖ ជាប្រភេទគណនី សម្រាប់បើកជូនអតិថិជនជារូបវន្តបុគ្គលប្រើប្រាស់ និងធ្វើប្រតិបត្តិការសាច់ប្រាក់ទៅតាមតម្រូវការផ្ទាល់ខ្លួន។
- **គណនីឯកត្តជនផ្ទាល់ខ្លួន** ៖ ជាប្រភេទគណនីឯកត្តជន ដែលមានម្ចាស់តែម្នាក់គត់។

- **គណនីឯកត្តជនរួម** ៖ ជាប្រភេទគណនីឯកត្តជន ដែលមានសមាជិករួមគណនី (គណនី) ចាប់ពី 02 នាក់ឡើងទៅ។
- **គណនីនីតិបុគ្គល** ៖ ជាប្រភេទគណនី សម្រាប់បើកជូនអតិថិជនជានីតិបុគ្គល (បើកគណនីក្រោមឈ្មោះស្ថាប័ន) ប្រើប្រាស់ និងធ្វើប្រតិបត្តិការសាច់ប្រាក់ទៅតាមតម្រូវការ។
- **លេខកូដសម្ងាត់** (PIN) ៖ គឺជាលេខកូដសម្ងាត់ផ្ទាល់ខ្លួនចំនួន **០៦ ខ្ទង់** (ជាលេខសុទ្ធ) ដែលត្រូវបានកំណត់ដោយផ្ទាល់ពីលោក-លោកស្រី នៅពេលចុះឈ្មោះប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ពាណិជ្ជករ។ លេខកូដសម្ងាត់នេះត្រូវបានប្រើដើម្បីចូលទៅប្រើប្រាស់ (Login) កម្មវិធីខេប៊ីប្រាសាក់ពាណិជ្ជករ។
- **លេខកូដ** OTP ៖ មានពាក្យពេញគឺ One Time Password (OTP) ដែលជាលេខកូដសម្ងាត់ចំនួន **០៦ ខ្ទង់** ផ្សេងមួយទៀត ដែលត្រូវបានបង្កើតឡើងដោយស្វ័យប្រវត្តិពីប្រព័ន្ធ និងត្រូវបានផ្ញើសារទៅកាន់លេខទូរស័ព្ទ របស់លោក-លោកស្រី ដើម្បីអនុម័តលើការចុះឈ្មោះប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ពាណិជ្ជករ។ **លេខកូដ** នេះមានសុពលភាពប្រើប្រាស់បានតែមួយដង ឬ មួយប្រតិបត្តិការគត់។
- **ការស្កេនស្នាមខ្ចៅដៃ/ផ្ទៃមុខ** ៖ សំដៅដល់ប្រព័ន្ធសុវត្ថិភាពនៃការស្កេនស្នាមខ្ចៅដៃ ឬ ផ្ទៃមុខនៅលើទូរស័ព្ទចល័ត (Fingerprint/Facial Recognition) សម្រាប់បញ្ជាក់អត្តសញ្ញាណអតិថិជននៅពេលចូលប្រើទូរស័ព្ទ ឬ សេវាខេប៊ីប្រាសាក់ពាណិជ្ជករ បន្ថែមពីលើការប្រើប្រាស់ **លេខកូដសម្ងាត់** (PIN)។ លោក-លោកស្រី អាចកំណត់ការចូលប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ពាណិជ្ជករ ដោយប្រើការស្កេនស្នាមខ្ចៅដៃ/ផ្ទៃមុខ លុះត្រាតែ លោក-លោកស្រី បានកំណត់ លក្ខខណ្ឌសុវត្ថិភាពនេះសម្រាប់ការចូលទៅប្រើប្រាស់ទូរស័ព្ទចល័តរបស់ លោក-លោកស្រី ជាមុន។
- **ផ្ទេរត្រឡប់** ៖ សំដៅដល់ប្រតិបត្តិការផ្ទេរប្រាក់ត្រលប់ទៅកាន់អតិថិជនវិញ ករណីទូទាត់លើសឬ ស្ងួន ឬ មានការស្នើសុំមោឃភាពប្រតិបត្តិការទូទាត់ពីអតិថិជន ដែលបានទិញទំនិញ ឬ ប្រើប្រាស់សេវាកម្មផ្សេងៗ ដែលកើតមានឡើងក្នុងថ្ងៃ។
- **របាយការណ៍លក់** ៖ សំដៅលើកំណត់ត្រានៃប្រតិបត្តិការលក់ចេញ ឬ ចូលទាំងឡាយនៅក្នុងគណនីដែលលោក-លោកស្រីអាចពិនិត្យតាមរយៈកម្មវិធីខេប៊ីប្រាសាក់ពាណិជ្ជករ។
- **ករណីប្រធានសក្តិ** ៖ សំដៅលើអំពើទាំងឡាយណា ដែលកើតឡើងក្រៅពីឆន្ទៈ ដោយមិនអាចប៉ាន់ស្មានជាមុន និងមិនអាចជំនះបាន ឬ ដែលមិនអនុញ្ញាតឱ្យភាគីណាមួយ ឬ ទាំងពីរអាចបន្តបំពេញកាតព្វកិច្ចរបស់ខ្លួនជាប្រក្រតីបានដូចជា៖ បន្ទុះភ្នំភ្លើង ទឹកជំនន់ គ្រោះរញ្ជួយដី ព្យុះសង្ឃរា ភេរវកម្ម កុបកម្ម សង្គ្រាម។ល។

3. ប្រភេទមុខងារសំខាន់ៗនៃសេវាខេប៊ីប្រាសាក់ពាណិជ្ជករ

- ចុះឈ្មោះប្រើប្រាស់សេវាខេប៊ីប្រាសាក់ពាណិជ្ជកររដោយខ្លួនឯង សម្រាប់អតិថិជនមានគណនីស្រាប់ (Online Self-Registration) ដូចជា៖
  - គណនីឯកត្តជន (Individual Single Account) ឬ
  - គណនីរួម (Joint Account) ជាមួយលក្ខខណ្ឌប្រតិបត្តិការគណនី «ម្នាក់មានសិទ្ធិចុះហត្ថលេខា (Anyone to Signing)»
  - គណនីនីតិបុគ្គល
- បង្កើតហាងដោយខ្លួនឯងបានយ៉ាងងាយស្រួល
- ភ្ជាប់គណនីដោយខ្លួនឯង សម្រាប់ការទូទាត់ទំនិញ និងសេវាកម្ម
- ធ្វើការផ្លាស់ប្តូរគណនីសន្សំ ឬ គណនីចម្រើនគ្មានកាលកំណត់ ឬ គណនីចម្រើនតាមលំដាប់ ឬ គណនីឌីជីថល ទៅជាគណនីសន្សំពាណិជ្ជករ
- គ្រប់គ្រង ចាត់ចែង និងរៀបចំបុគ្គលិកទៅតាមតួនាទីដូចជា សហពាណិជ្ជករ អ្នកគ្រប់គ្រងហាង និងអ្នកគិតលុយ
- ផ្លាស់ប្តូរបុគ្គលិក (បន្ថែម ឬ ដកចេញ) រួមមាន សហពាណិជ្ជករ អ្នកគ្រប់គ្រងហាង និងអ្នកគិតលុយ
- បើកដំណើរការ ឬ បិទបញ្ជរ
- បើកដំណើរការ ឬ បិទហាងទំនិញ
- កែប្រែឈ្មោះហាង ឬ ព័ត៌មានផ្សេងៗ
- បើក ឬ បិទមុខងារផ្ទេរត្រឡប់
- បើក ឬ បិទមុខងារប្រាក់ធីប (Tipping)
- ពិនិត្យរបាយការណ៍លក់របស់បុគ្គលិកនីមួយៗ តាមបញ្ជរ ជាប្រចាំថ្ងៃ ប្រចាំខែ ឬ កាលបរិច្ឆេទណាមួយ
- ស្នើសុំសម្ភារៈជាខេអេចយ៉ូអរកូតពី ខេប៊ីប្រាសាក់
- ទទួលការទូទាត់ថ្លៃទំនិញ/សេវាកម្មតាមរយៈការស្កេនខេអេចយ៉ូអរកូត (ក្នុងគ្រឹះស្ថានតែមួយ ឬ ឆ្លងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ)
- ចែករំលែក KHQR Code និង Deep link
- ប្តូរលេខកូដសម្ងាត់ (PIN)
- កំណត់លេខកូដសម្ងាត់ថ្មី ករណីភ្លេច
- មុខងារផ្សេងៗ។

4. ការចុះឈ្មោះប្រើប្រាស់សេវាខេប៊ីប្រាសាក់ពាណិជ្ជករ

4.1. លក្ខខណ្ឌតម្រូវនៃការចុះឈ្មោះប្រើប្រាស់

ក) ជាអតិថិជនឯកត្តជន (Individual) ឬ នីតិបុគ្គល (Legal Entity)

ខ) ត្រូវមានគណនីប្រាក់បញ្ញើសន្សំនៅខេប៊ីប្រាសាក់ (គណនីឯកត្តជនផ្ទាល់ខ្លួន ឬ គណនីរួម ឬ គណនីនីតិបុគ្គល)

គ) ត្រូវមានទូរស័ព្ទ (Smart Phone) ដែលប្រតិបត្តិដោយប្រព័ន្ធ iOS ឬ Android និងលេខទូរស័ព្ទប្រើប្រាស់ជាកម្មសិទ្ធិផ្ទាល់ខ្លួន ហើយទូរស័ព្ទ និងលេខទូរស័ព្ទនេះត្រូវនៅជាមួយគ្នា

ឃ) ត្រូវដំឡើង **កម្មវិធីខេប៊ីប្រាសាក់ពាណិជ្ជករ** (KB PRASAC Merchant App) នៅលើទូរស័ព្ទជាមួយលេខទូរស័ព្ទដែលមានសុពលភាព និងជាលេខដែលបានផ្តល់មក ខេប៊ីប្រាសាក់ ពេលស្នើសុំបើកគណនី ឬ បានធ្វើបច្ចុប្បន្នភាពចុងក្រោយជាមួយ ខេប៊ីប្រាសាក់

ង) ត្រូវបញ្ចូលព័ត៌មានចាំបាច់មួយចំនួនរួមមាន **លេខទូរស័ព្ទ និង លេខគណនី** ឱ្យបានត្រឹមត្រូវទៅតាមនីតិវិធីតម្រូវនៃប្រព័ន្ធសម្រាប់ការចុះឈ្មោះប្រើប្រាស់

ច) ត្រូវកំណត់**លេខកូដសម្ងាត់** (PIN) ផ្ទាល់ខ្លួន ចំនួន 06ខ្ទង់ សម្រាប់ចូលប្រើប្រាស់ (Login) សេវាខេប៊ីប្រាសាក់ពាណិជ្ជករដោយខ្លួនឯង និង/ឬ អាចកំណត់ការ**ស្កេនស្នាមខ្ទៅដៃ/ផ្ទៃមុខ** (Fingerprint/Facial Recognition) ដើម្បីបង្កើនសុវត្ថិភាពនៃការចូលប្រើប្រាស់សេវាខេប៊ីប្រាសាក់ពាណិជ្ជករ

ឆ) ត្រូវយល់ព្រមគោរពតាម **លក្ខខណ្ឌនៃការប្រើប្រាស់សេវាខេប៊ីប្រាសាក់ពាណិជ្ជករ** នេះ។

4.2. នៅក្នុងដំណើរការនៃការចុះឈ្មោះប្រើប្រាស់សេវាខេប៊ីប្រាសាក់ពាណិជ្ជករ លោក-លោកស្រីនឹងទទួលបាន **លេខកូដ** One-Time Password (OTP) ចំនួន 06 ខ្ទង់ ដែលប្រព័ន្ធនឹងផ្ញើចូលទៅកាន់ប្រអប់សារលេខទូរស័ព្ទរបស់ លោក-លោកស្រី ដែលផ្តល់មក ខេប៊ីប្រាសាក់ ចុងក្រោយបំផុត ដើម្បីអនុម័តលើប្រតិបត្តិការនៃការស្នើសុំចុះឈ្មោះប្រើប្រាស់សេវាខេប៊ីប្រាសាក់ពាណិជ្ជករ។

4.3. បន្ទាប់ពីចុះឈ្មោះប្រើប្រាស់សេវាខេប៊ីប្រាសាក់ពាណិជ្ជករបានជោគជ័យ លោក-លោកស្រី អាចប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ពាណិជ្ជករទៅតាមមុខងារនីមួយៗនៃកម្មវិធីសេវាខេប៊ីប្រាសាក់ពាណិជ្ជករ។

4.4. **ការបង្កើតអាជីវកម្ម ឬ ហាង**

4.4.1. លោក-លោកស្រី អាចធ្វើការបង្កើតអាជីវកម្ម ឬ ហាង នៅក្នុងកម្មវិធីខេប៊ីប្រាសាក់ពាណិជ្ជករ ដោយមិនកំណត់។

4.4.2. ករណីលោក-លោកស្រី មានហាងច្រើន នោះការកំណត់ឈ្មោះហាង គឺត្រូវកំណត់ឈ្មោះផ្សេងៗគ្នា នៅក្នុងកម្មវិធីខេប៊ីប្រាសាក់ពាណិជ្ជករ ដោយ លោក-លោកស្រីអាចកំណត់ ឈ្មោះហាង បូក សាខាទី ១ ឬ ផ្សេងៗ។

4.4.3. លោក-លោកស្រី អាចកំណត់បុគ្គលិកដើម្បីគ្រប់គ្រងហាង ដូចជា សហពាណិជ្ជករ អ្នកគ្រប់គ្រងហាង អ្នកគិតលុយ ដោយមិនកំណត់ និងបត់បែនទៅតាមតម្រូវការអាជីវកម្មជាក់ស្តែង។

4.5. **លក្ខខណ្ឌភ្ជាប់គណនីទៅសេវាខេប៊ីប្រាសាក់ពាណិជ្ជករ**

4.5.1. តម្រូវឱ្យភ្ជាប់គណនី 02 សម្រាប់ហាងមួយ ជាមួយរូបិយប័ណ្ណគណនីខុសគ្នា គឺ គណនីប្រាក់រៀល និងគណនីប្រាក់ដុល្លារ។ លោក-លោកស្រី មិនអាចភ្ជាប់គណនី ដែលមានរូបិយប័ណ្ណដូចគ្នាសម្រាប់ហាងមួយបានទេ។

4.5.2. ជាគណនីនៅដំណើរការ និងជាគណនីផ្ទាល់ខ្លួន ឬ គណនីរួម ឬ គណនីនីតិបុគ្គល

4.5.3. គណនីទាំង 02 អាចភ្ជាប់ជាមួយអាជីវកម្ម ឬ ហាងផ្សេងៗទៀតបានដោយមិនកំណត់។

4.5.4. អ្នកមានសិទ្ធិភ្ជាប់គណនីទៅក្នុងកម្មវិធីខេប៊ីប្រាសាក់ពាណិជ្ជករ គឺជាម្ចាស់គណនី (Account Holder) ឬ អ្នកមានសិទ្ធិក្នុងគណនី (Account Signatory)។

5. ការស្នើសុំ និងទទួលខេអេចឃ្យូអរកូត និងសម្ភារៈពាក់ព័ន្ធ

5.1. លោក-លោកស្រី អាចស្នើសុំខេអេចឃ្យូអរកូតពី ខេប៊ីប្រាសាក់ តាមរយៈកម្មវិធីខេប៊ីប្រាសាក់ពាណិជ្ជករ សម្រាប់ហាងនីមួយៗ ដោយអាចកំណត់ចំនួនស្នើសុំ ប្រភេទ និងលក្ខខណ្ឌប្រគល់ទទួលដូចខាងក្រោម៖

ក) ប្រភេទខេអេចឃ្យូអរកូត៖ ជើងបញ្ឈរដាក់លើតុ ខ្សែកាត ស្ទីកគ័រទំហំ A6

ខ) ចំនួនខេអេចឃ្យូអរកូត៖ មិនកំណត់ និងស្នើសុំបានតាមតម្រូវការជាក់ស្តែង

គ) ការប្រគល់ទទួល៖ ដឹកជញ្ជូនដល់ទីកន្លែង ឬ មកទទួលយកនៅសាខា។

5.2. លោក-លោកស្រី តម្រូវឱ្យធ្វើការត្រួតពិនិត្យព័ត៌មាននៅលើខេអេចឃ្យូអរកូតដែលប្រគល់ជូនឱ្យបានត្រឹមត្រូវមុនទទួលយក។

5.3. រាល់ការទទួលយកខេអេចឃ្យូអរកូតដែលមានព័ត៌មានខុសពីការស្នើសុំរបស់លោក-លោកស្រី ជាការទទួលខុសត្រូវទាំងស្រុងរបស់លោក-លោកស្រី។

6. ការទូទាត់ទំនិញ/សេវាកម្ម

6.1. អាចទទួលការទូទាត់ពីគ្រប់អតិថិជន (អតិថិជនរបស់ខេប៊ីប្រាសាក់ និងអតិថិជនធនាគារផ្សេង) តាមរយៈការស្កេនខេអេចឃ្យូអរកូត ដែលបានបង្កើតតាមរយៈកម្មវិធីខេប៊ីប្រាសាក់ពាណិជ្ជករ

6.2. អាចទទួលការទូទាត់ពីគ្រប់អតិថិជន តាមរយៈការស្កេន ខេអេចឃ្យូអរកូត នៅក្នុងជើងបញ្ឈរ ឬ ខ្សែកាត ឬ ស្ទីកគ័រ ឬ សៀវភៅដាក់វិក្កយបត្រ ដែលបានស្នើសុំដោយផ្ទាល់តាមសាខាខេប៊ីប្រាសាក់

6.3. អាចកំណត់ចំនួនទឹកប្រាក់ សម្រាប់ទទួលការទូទាត់ នៅក្នុងខេអេចឃ្យូអរកូត ដែលបង្កើតចេញពីក្នុងកម្មវិធីខេប៊ីប្រាសាក់ពាណិជ្ជករបាន។ល។

7. ប្រតិបត្តិការទូទាត់ពីខេប៊ីប្រាសាក់

7.1. ខេប៊ីប្រាសាក់នឹងធ្វើការទូទាត់នូវប្រតិបត្តិការទាំងឡាយណា ដែលបានទទួលតាមរយៈការស្កេនខេអេចឃ្យូអរកូត ទៅក្នុងគណនីរបស់លោក-លោកស្រីភ្លាមៗ។

7.2. ខេប៊ីប្រាសាក់ មានសិទ្ធិពេញលេញក្នុងការបង្ខាំងទុកសាច់ប្រាក់ទូទាត់ ដែលមានជម្លោះ ឬ ប្រតិបត្តិការមិនប្រក្រតីណាមួយ ដើម្បីធ្វើការដោះស្រាយតាមគោលការណ៍ខេប៊ីប្រាសាក់ និងតាមផ្លូវច្បាប់។

7.3. លោក-លោកស្រីបានផ្តល់សិទ្ធិដល់ខេប៊ីប្រាសាក់ក្នុងការទូទាត់សាច់ប្រាក់ដោយស្វ័យប្រវត្តិដោយកាត់ចេញពីគណនីរបស់លោក-លោកស្រី ក្នុងករណីដូចខាងក្រោម៖

- កម្រៃសេវាផ្សេងៗដែលខេប៊ីប្រាសាក់បានជូនដំណឹងទៅលោក-លោកស្រី
- សាច់ប្រាក់បង្វិលសងមកខេប៊ីប្រាសាក់វិញ (Reversal) ប្រសិនបើមាន
- ទឹកប្រាក់ដែលខេប៊ីប្រាសាក់បានបញ្ចូលទៅក្នុងគណនីរបស់លោក-លោកស្រី ពាក់ព័ន្ធនឹងប្រតិបត្តិការភាន់ច្រលំ
- ទឹកប្រាក់ប្រតិបត្តិការ ដែលអ្នកផ្ញើរ ឬ អ្នកទូទាត់មិនព្រមទូទាត់ ហើយ លោក-លោកស្រី មិនមានឯកសារគាំទ្រគ្រប់គ្រាន់ ឬ ផ្តល់ឯកសារគាំទ្រនោះយឺតយ៉ាវបន្ទាប់ពីខេប៊ីប្រាសាក់បានជូនដំណឹង

- ទឹកប្រាក់នៃប្រតិបត្តិការ ដែលអ្នកផ្ទេរ ឬ អ្នកទូទាត់ ឬ ខេប៊ីប្រាសាក់មិនទទួលស្គាល់ដោយសារជាប្រតិបត្តិការក្លែងបន្លំ (Fraud Transaction) ដោយលោក-លោកស្រីមិនមានឯកសារគាំទ្រលក់ត្រឹមត្រូវ ឬ ឯកសារ បន្លំ។ល។

8. ការផ្អៀងផ្ទាត់ប្រតិបត្តិការ

8.1. លោក-លោកស្រីត្រូវត្រួតពិនិត្យប្រតិបត្តិការ និងរបាយការណ៍គណនីរបស់ខ្លួនឱ្យបានជាប្រចាំ។ ករណីមានភាពមិនត្រឹមត្រូវ លោក-លោកស្រីត្រូវជូនដំណឹងជាបន្ទាន់មកខេប៊ីប្រាសាក់។

8.2. ករណីប្រតិបត្តិការទូទាត់ពីខេប៊ីប្រាសាក់មិនត្រឹមត្រូវ លោក-លោកស្រីត្រូវជូនដំណឹងមកខេប៊ីប្រាសាក់ និងត្រូវភ្ជាប់ជាមួយវិក្កយប័ត្រ ឬ ឯកសារផ្សេងៗពាក់ព័ន្ធនឹងការលក់ (ករណីមាន) ដើម្បីធ្វើការផ្អៀងផ្ទាត់ប្រតិបត្តិការឡើងវិញ។

9. ម៉ោងប្រតិបត្តិការ

9.1. អាចធ្វើប្រតិបត្តិការតាមរយៈសេវាខេប៊ីប្រាសាក់ពាណិជ្ជករបាន 24 ម៉ោង ជាប្រចាំថ្ងៃ (24/7) លើកលែងតែមានការផ្អាកជាបណ្តោះអាសន្នដោយមានការជូនដំណឹងពីខេប៊ីប្រាសាក់។

9.2. ខេប៊ីប្រាសាក់ នឹងធ្វើការជូនដំណឹងដល់ លោក-លោកស្រី ករណីមានការផ្អាកប្រតិបត្តិការដើម្បីជួសជុល ឬ ធ្វើបច្ចុប្បន្នភាពប្រព័ន្ធ។

9.3. ខេប៊ីប្រាសាក់ រក្សាសិទ្ធិក្នុងការផ្អាកប្រតិបត្តិការពេលមានបញ្ហាផ្សេងៗ ឬ ពេលមានការចាំបាច់ណាមួយ។

10. រូបិយប័ណ្ណ និងអត្រាប្តូរប្រាក់

10.1. លោក-លោកស្រី អាចប្រើប្រាស់សេវាខេប៊ីប្រាសាក់ពាណិជ្ជករ ដើម្បីទទួលការទូទាត់ជាមួយរូបិយប័ណ្ណចំនួន 02 (ពីរ) ប្រភេទ រួមមាន៖

- ប្រាក់រៀល (KHR) និង
- ប្រាក់ដុល្លារអាមេរិក (USD)

10.2. រាល់ប្រតិបត្តិការទូទាត់ឆ្លងរូបិយប័ណ្ណ អត្រាប្តូរប្រាក់ត្រូវយោងទៅតាមអត្រាប្តូរប្រាក់ប្រចាំថ្ងៃរបស់ ខេប៊ីប្រាសាក់ នៅក្នុងថ្ងៃ និងម៉ោងនៃការធ្វើប្រតិបត្តិការ។

11. ទំហំកំណត់នៃប្រតិបត្តិការ និងកម្រៃសេវា

11.1. លោក-លោកស្រី អាចស្វែងរកព័ត៌មានស្តីអំពីកម្រៃសេវា និង/ឬ ទំហំកំណត់ នៅលើគេហទំព័រផ្លូវការរបស់ ខេប៊ីប្រាសាក់ និង/ឬ គ្រប់សាខាខេប៊ីប្រាសាក់ និង/ឬ សេវាខេប៊ីប្រាសាក់ពាណិជ្ជករ។

11.2. លោក-លោកស្រី យល់ព្រម បង់កម្រៃសេវាផ្សេងៗ ពាក់ព័ន្ធទៅនឹងការប្រើប្រាស់សេវាខេប៊ីប្រាសាក់ពាណិជ្ជករ ព្រមទាំងយល់ព្រមឱ្យខេប៊ីប្រាសាក់ ទូទាត់កម្រៃសេវាដោយផ្ទាល់ចេញពីគណនីរបស់ លោក-លោកស្រី ដោយពុំចាំបាច់ធ្វើការជូនដំណឹងជាមុនឡើយ។

12. សារជូនដំណឹង

លោក-លោកស្រី នឹងទទួលបានសារជូនដំណឹងតាមរយៈកម្មវិធីខេប៊ីប្រាសាក់ពាណិជ្ជករ ស្តីអំពីការចុះឈ្មោះប្រើប្រាស់ពាណិជ្ជករ និងប្រតិបត្តិការទូទាត់ និងការជូនដំណឹងផ្សេងៗ លើកលែងតែមានភាពរអាក់រអួលពីប្រព័ន្ធ។

13. លក្ខណៈផ្សេងៗសម្រាប់ការប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ពាណិជ្ជករ

រាល់ការបញ្ចូលលេខកូដសម្ងាត់ (PIN) ឬ លេខកូដ OTP ខុស 03 ដង នោះសេវាខេប៊ីប្រាសាក់ពាណិជ្ជករ នឹងត្រូវបានបង្ខាំងរយៈ ០៥ នាទី។ ករណីអតិថិជនបញ្ចូលលេខកូដសម្ងាត់ខុសលើកទី២ឡើងទៅ រយៈពេលនៃការបង្ខាំងនឹងត្រូវកើនឡើងចំនួន ២ដងនៃ រយៈពេលនៃការបង្ខាំងលើកទី១។ លោក-លោកស្រី អាចទាក់ទងមក ខេប៊ីប្រាសាក់ តាមរយៈលេខ 023/086 999 911 ឬ អញ្ជើញមកសាខា ខេប៊ីប្រាសាក់ ណាមួយដើម្បីស្នើសុំដោះបង្ខាំង។

14. ការបញ្ឈប់ការប្រើប្រាស់សេវាខេប៊ីប្រាសាក់ពាណិជ្ជករ

លោក-លោកស្រី អាចស្នើសុំបញ្ឈប់ការប្រើប្រាស់សេវាខេប៊ីប្រាសាក់ពាណិជ្ជករ ជាលាយលក្ខណ៍អក្សរបាន ដោយត្រូវអញ្ជើញទៅកាន់សាខាខេប៊ីប្រាសាក់ ណាមួយដែលនៅជិតបំផុត។

15. ការប្តូរប្រភេទគណនី

15.1. លោក-លោកស្រី ដែលជាម្ចាស់គណនីឯកត្តជន (Individual) និងជាប្រភេទគណនីឯកត្តជនផ្ទាល់ខ្លួន (Single Account) អាចធ្វើការផ្លាស់ប្តូរប្រភេទគណនីប្រាក់បញ្ញើសន្សំរបស់ខ្លួន (អាចជា គណនីសន្សំ ឬ គណនីចម្រើនគ្មានកាលកំណត់ ឬ គណនីចម្រើនតាមលំដាប់ ឬ គណនីឌីជីថល) ទៅជា គណនីសន្សំពាណិជ្ជករ (Merchant Savings Account) បានដោយខ្លួនឯង តាមរយៈកម្មវិធីខេប៊ីប្រាសាក់ពាណិជ្ជករ។

15.2. បន្ទាប់ពីបានធ្វើការផ្លាស់ប្តូរប្រភេទគណនីរួចរាល់តាមរយៈកម្មវិធីខេប៊ីប្រាសាក់ពាណិជ្ជករ លោក-លោកស្រី យល់ព្រមគោរព និងប្រើប្រាស់គណនីសន្សំពាណិជ្ជករឱ្យបានត្រឹមត្រូវទៅតាមលក្ខណៈ និងលក្ខខណ្ឌនៃការប្រើប្រាស់គណនីសន្សំពាណិជ្ជករ ដែលអាចស្វែងរកបាននៅតាមសាខាខេប៊ីប្រាសាក់ និង/ឬ វេបសាយត៍ផ្លូវការរបស់ខេប៊ីប្រាសាក់។

15.3. រាល់ការទូទាត់ដែលទទួលបានតាមរយៈសេវាខេប៊ីប្រាសាក់ពាណិជ្ជករ នឹងត្រូវបញ្ចូលទៅក្នុងគណនីសន្សំពាណិជ្ជករដោយស្វ័យប្រវត្តិ។

16. សុវត្ថិភាពលើការប្រើប្រាស់សេវាខេប៊ីប្រាសាក់ពាណិជ្ជករ

16.1. សុវត្ថិភាពលើទូរស័ព្ទ

16.1.1. សូមកំណត់លេខសម្ងាត់ (Password) ឬ កំណត់ការស្កេនស្នាមខ្ចៅដៃ/ផ្ទៃមុខ (Fingerprint / Facial Recognition) ដើម្បីការពារទូរស័ព្ទដៃ របស់លោក-លោកស្រី ពីការចូលមើល ឬ ប្រើប្រាស់ពីបុគ្គលផ្សេងដោយគ្មានការអនុញ្ញាត។

16.1.2. មិនត្រូវផ្តល់ ឬ បង្ហាញ **លេខសម្ងាត់ (Password)** ឬ អនុញ្ញាតឱ្យបុគ្គលណាម្នាក់ធ្វើការកំណត់ **លេខសម្ងាត់ ឬ ស្កេនស្នាមខ្ចៅដៃ / ផ្ទៃមុខ** ឬ ចូលប្រើប្រាស់ទូរស័ព្ទដៃ ជំនួស លោក-លោកស្រី ជាដាច់ខាត បើទោះបីជាបុគ្គលនោះជា អ្នករួមគណនី ឬ សាច់ញាតិ ឬ មិត្តភក្តិ ឬ បុគ្គលិកខេប៊ីប្រាសាក់ ក៏ដោយ។

16.1.3. មិនត្រូវកត់ត្រាលេខសម្ងាត់ (Password) ដើម្បីចូលប្រើប្រាស់ទូរស័ព្ទដៃនៅក្នុងទូរស័ព្ទជាដាច់ខាត។

16.1.4. ត្រូវប្រាកដថារាល់ការបញ្ចូលលេខសម្ងាត់ (Password) ដើម្បីចូលប្រើប្រាស់ទូរស័ព្ទដៃ របស់លោក-លោកស្រី មិនត្រូវបានលួចមើល ឬ ដឹងដោយបុគ្គលណាម្នាក់ឡើយ។

16.1.5. ត្រូវធ្វើការផ្លាស់ប្តូរ លេខសម្ងាត់ (Password) ទូរស័ព្ទដៃ របស់លោក-លោកស្រី ឱ្យបានញឹកញាប់ ឬ ករណីសង្ស័យថាលេខសម្ងាត់ត្រូវបានដឹងដោយបុគ្គលណាម្នាក់។

16.1.6. សូមកុំប្រើទូរស័ព្ទដៃ ដែលប្រើប្រាស់សេវាខេប៊ីប្រាសាក់ពាណិជ្ជករ ទៅភ្ជាប់ជាមួយសេវាអ៊ីនធឺណែតសាធារណៈ ឬ ប្រើរួមជាមួយអ្នកដទៃ ដើម្បីចៀសវាងពីការបន្លំលួចដោយ Hacker។

16.1.7. មិនត្រូវភ្ជាប់ប្រព័ន្ធ ឬ បញ្ចូលកម្មវិធី ដែលមិនស្គាល់ក្នុងទូរស័ព្ទ ឡើយ។ ករណីបានភ្ជាប់ ត្រូវផ្តាច់ ឬ លុបចេញ និងសម្អាតភ្លាមៗ ដើម្បីចៀសវាងការឆ្លងមេរោគ ឬ ការបន្លំលួចប្រាក់របស់លោក-លោកស្រី (Virus and/or Hacker)។

16.1.8. ត្រូវដំឡើងសេវាខេប៊ីប្រាសាក់ពាណិជ្ជករ និងធ្វើបច្ចុប្បន្នភាពលើកម្មវិធីទូរស័ព្ទ ដោយផ្ទាល់ពី Play Store ឬ App Store ។

16.1.9. សូមកុំទុកទូរស័ព្ទដៃ ដែលកំពុងបើកសេវាខេប៊ីប្រាសាក់ពាណិជ្ជករ ចោលនៅទីសាធារណៈ និងត្រូវចាក់សោទូរស័ព្ទ (Lock Phone) ភ្លាមៗករណីឈប់ប្រើប្រាស់។

16.1.10. ករណីលោក-លោកស្រី លក់ ឬ ជួសជុល ឬ ផ្ទេរទូរស័ព្ទ ឱ្យអ្នកផ្សេង ត្រូវលុបសេវាខេប៊ីប្រាសាក់ពាណិជ្ជករ ឬ ព័ត៌មានពាក់ព័ន្ធផ្សេងៗចេញពីក្នុងទូរស័ព្ទដៃ ឱ្យបានរួចរាល់ជាមុន ។

16.1.11. ករណីបាត់ទូរស័ព្ទ ឬ សង្ស័យមានអ្នកផ្សេងស្គាល់លេខសម្ងាត់ចូលប្រើប្រាស់ទូរស័ព្ទដៃ ត្រូវជូនដំណឹងមក ខេប៊ីប្រាសាក់ ជាបន្ទាន់តាមរយៈលេខ 023/086 999 911 ដើម្បីបង្ខាំងសេវាខេប៊ីប្រាសាក់ពាណិជ្ជករ ឬ ចាត់វិធានការផ្សេងៗតាមលក្ខណៈបច្ចេកទេស ដើម្បីទប់ស្កាត់ការបន្លំធ្វើប្រតិបត្តិការ។

16.2. សុវត្ថិភាពលើលេខកូដសម្ងាត់

16.2.1. សូមចងចាំលេខកូដសម្ងាត់ (PIN) របស់លោក-លោកស្រី ហើយកុំកត់ត្រាលើអ្វីមួយ ឬ ឱ្យអ្នកដទៃដឹង។

16.2.2. សូមរក្សាលេខកូដសម្ងាត់ (PIN) ឬ លេខកូដ OTP និងព័ត៌មានផ្សេងៗរបស់លោក-លោកស្រីឱ្យមានសុវត្ថិភាព។ រាល់ការខូចខាតដែលកើតចេញពីការធ្វេសប្រហែសក្នុងការរក្សាព័ត៌មានសម្ងាត់ខាងលើ គឺជាការទទួលខុសត្រូវទាំងស្រុងរបស់លោក-លោកស្រី។

16.2.3. សូមកុំផ្តល់ ឬ ផ្ញើលេខកូដសម្ងាត់(PIN) ឬ លេខកូដ OTP ឬ ព័ត៌មានផ្ទាល់ខ្លួនដល់នរណាម្នាក់ឡើយ ទោះដោយផ្ទាល់មាត់ ឬ តាមរយៈផ្ញើសារអេឡិចត្រូនិកអាចជា អ៊ីម៉ែល Facebook Messenger ឬ តេលេក្រាម(Telegram)... ជាដើម។

16.2.4. សូមកុំប្រើ ថ្ងៃខែឆ្នាំកំណើត ឬ លេខទូរស័ព្ទ ឬ លេខគណនី ឬ លេខអត្តសញ្ញាណប័ណ្ណ ឬ លេខរៀងដែលងាយស្រួលចាំ ឬ ស្រួលស្មានដឹង (ឧ. 111111 ឬ 123456...) មកធ្វើជា លេខកូដសម្ងាត់ (PIN) ដើម្បីចូលប្រើប្រាស់សេវាខេប៊ីប្រាសាក់ពាណិជ្ជករ។

16.2.5. ប្រសិនបើមានការកត់សម្គាល់ណាមួយដែលបង្ហាញថា ស្រោមសំបុត្រលេខកូដសម្ងាត់របស់លោក-លោកស្រីត្រូវគេហែកមើលនោះ សូមទាក់ទងមកសាខាខេប៊ីប្រាសាក់ ដែលនៅជិតលោក-លោកស្រីជាបន្ទាន់។

16.2.6. ត្រូវធានាឱ្យច្បាស់ថា រាល់ពេល លោក-លោកស្រី បញ្ចូលលេខកូដសម្ងាត់ (PIN) ដើម្បីចូលប្រើប្រាស់សេវាខេប៊ីប្រាសាក់ពាណិជ្ជករ មិនត្រូវបានអ្នកដទៃឃ្លាំមើល ឬ ក៏មានមនុស្សនៅក្បែរអ្នកឡើយ។

16.2.7. សូមធ្វើការផ្លាស់ប្តូរលេខកូដសម្ងាត់ (PIN) ឱ្យបានញឹកញាប់ និង/ឬ ក្នុងករណីសង្ស័យថា លេខកូដសម្ងាត់ (PIN) ត្រូវបានដឹងដោយអ្នកដទៃ។

16.2.8. លោក-លោកស្រី គួរកំណត់លេខកូដសម្ងាត់ (PIN) ចូលប្រើប្រាស់សេវាខេប៊ីប្រាសាក់ពាណិជ្ជករ ឱ្យខុសពី លេខសម្ងាត់ (Password) បើកសោទូរស័ព្ទដៃរបស់ខ្លួន។

16.2.9. ត្រូវជូនដំណឹងមក ខេប៊ីប្រាសាក់ ជាបន្ទាន់ប្រសិនបើ លោក-លោកស្រី ភ្លេចលេខកូដសម្ងាត់ (PIN) ឬ សង្ស័យអ្នកផ្សេងបានដឹង។

16.3. សារបោកបញ្ឆោតតាមរយៈអ៊ីម៉ែល ឬ ទូរស័ព្ទ

16.3.1. សូមប្រុងប្រយ័ត្នការបោកបញ្ឆោតយកព័ត៌មាន តាមរយៈទូរស័ព្ទ អ៊ីម៉ែល វេបសាយត៍ កម្មវិធីដែលលោតផ្ទាំងមក (pop-up message) ឬ សារ (SMS) ដែលជាល្បិចកល ឱ្យ លោក-លោកស្រី បញ្ចូលព័ត៌មានសំខាន់ៗ ដូចជា៖ លេខកូដសម្ងាត់ (PIN) ឬ លេខកូដ OTP ឬ លេខទូរស័ព្ទ (Phone) ឬ ថ្ងៃខែឆ្នាំកំណើត (Date of Birth) ឬ ព័ត៌មានផ្ទាល់ខ្លួនផ្សេងៗជាដើម។ល។

16.3.2. ខេប៊ីប្រាសាក់ នឹងមិនស្នើសុំ លោក-លោកស្រី ឱ្យប្រាប់ពី លេខកូដសម្ងាត់ (PIN) និង/ឬ លេខកូដ OTP ដើម្បីចូលប្រើប្រាស់សេវាខេប៊ីប្រាសាក់ពាណិជ្ជករឡើយ ទោះបីជាសុំដោយផ្ទាល់មាត់តាម រយៈទូរស័ព្ទ ឬ អ៊ីម៉ែល ឬ តាមមធ្យោបាយទំនាក់ទំនងណាមួយ។

16.3.3. ប្រសិនបើ លោក-លោកស្រី ទទួលបានអ៊ីម៉ែល ឬ សារទូរស័ព្ទ ឬ ការហៅទូរស័ព្ទ ដែលស្នើសុំព័ត៌ មានខាងលើ សូមលុបចោល ឬ បដិសេធជាបន្ទាន់ និង/ឬ មិនត្រូវចុចលើតំណភ្ជាប់បណ្តាញ (Link) ឬ បើកឯកសារភ្ជាប់ណាមួយដែលមាននៅក្នុងអ៊ីម៉ែលនោះឡើយ។

16.3.4. ប្រសិនបើ លោក-លោកស្រី មានចម្ងល់ ឬ ក៏មានមន្ទិលសង្ស័យលើវេបសាយត៍ ឬ អ៊ីម៉ែលណាមួយ សូមទាក់ទងមកយើងខ្ញុំតាមរយៈ info@kbprasacbank.com.kh ឬ ទូរស័ព្ទលេខ 023/086 999 911។

17. សិទ្ធិ និងកាតព្វកិច្ចរបស់លោក-លោកស្រី

17.1. ត្រូវរៀបចំទីតាំងឱ្យបានសមរម្យសម្រាប់ដាក់ខេអេចឃ្យូអរកូតខេប៊ីប្រាសាក់ ដើម្បីផ្តល់ភាពងាយស្រួល និងមានសុវត្ថិភាពដល់អ្នកទូទាត់នៅពេលធ្វើប្រតិបត្តិការទូទាត់ទំនិញ ឬ សេវាកម្មផ្សេងៗ។

17.2. ត្រូវជួយសហការក្នុងការផ្សព្វផ្សាយជាសាធារណៈ ពីសេវាទូទាត់តាមរយៈសេវាខេប៊ីប្រាសាក់ពាណិជ្ជករ ឬ ខេអេចឃ្យូអរកូតរបស់ខេប៊ីប្រាសាក់ទៅដល់អតិថិជនរបស់ខ្លួន។

17.3. លោក-លោកស្រី ត្រូវធានាថាគ្រប់ព័ត៌មានដែលបានផ្តល់មក ខេប៊ីប្រាសាក់ ជាព័ត៌មានត្រឹមត្រូវ និង ថ្មីបំផុត។ ករណី លោក-លោកស្រី ផ្តល់ព័ត៌មានមិនពិត ឬ ក្លែងក្លាយ នោះ លោក-លោកស្រី ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់។

17.4. រាល់ប្រតិបត្តិការធ្វើឡើងតាមរយៈសេវាខេប៊ីប្រាសាក់ពាណិជ្ជករ ត្រូវអនុលោមត្រឹមត្រូវទៅតាម លក្ខខណ្ឌប្រើប្រាស់ ដែលបានព្រមព្រៀងជាមួយខេប៊ីប្រាសាក់ និងស្របតាមប្រភេទអាជីវកម្មពិតប្រាកដរបស់ខ្លួន។

17.5. លោក-លោកស្រី ត្រូវធានាថា មិនបានលក់ផលិតផលក្លែងក្លាយ ឬ ក្លែងបន្លំទំនិញដល់អតិថិជន ដែលបានទូទាត់តាមរយៈសេវាខេប៊ីប្រាសាក់ពាណិជ្ជករ ឬ ខេអេចឃ្យូអរកូតខេប៊ីប្រាសាក់ឡើយ។ ករណីមានបណ្តឹងកើតឡើង លោក-លោកស្រី ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ទាំងស្រុង។

17.6. ត្រូវរក្សាព័ត៌មាន និងឯកសារយោងផ្សេងៗ ពាក់ព័ន្ធនឹងប្រតិបត្តិការទូទាត់ជាការសម្ងាត់ លើកលែងតែមានការស្នើសុំពីខេប៊ីប្រាសាក់។

17.7. មិនត្រូវប្រព្រឹត្ត ឬ សហការជាមួយជនទុច្ចរិតក្នុងការបំពាក់ឧបករណ៍ផ្សេងៗ ដើម្បីចតចម្លង (Skim) យកព័ត៌មានសំខាន់ៗរបស់សេវាខេប៊ីប្រាសាក់ពាណិជ្ជករ ឬ កម្មវិធីផ្សេងៗរបស់ខេប៊ីប្រាសាក់ឡើយ។

17.8. លោក-លោកស្រីត្រូវធ្វើការត្រួតពិនិត្យកម្រៃសេវា និងព័ត៌មាននៃការទូទាត់ឱ្យបានត្រឹមត្រូវមុននឹងបញ្ជាការទូទាត់ត្រឡប់នៅក្នុងសេវាខេប៊ីប្រាសាក់ពាណិជ្ជករ។ រាល់ការបញ្ជាការទូទាត់ត្រឡប់ខុស ឬ លើស ឬ ខ្វះ ជាដើម ជាការទទួលខុសត្រូវទាំងស្រុងរបស់លោក-លោកស្រី។

17.9. លោក-លោកស្រី យល់ព្រមទូទាត់សងមកខេប៊ីប្រាសាក់ នូវចំនួនទឹកប្រាក់តាមទំហំខូចខាត និងរាល់ការចំណាយដែលកើតឡើងដោយការមិនគោរពច្បាប់ ឬ មិនបានគោរពតាមលក្ខខណ្ឌប្រើប្រាស់នេះ ឬ លក្ខខណ្ឌប្រើប្រាស់ទូទៅនៃផលិតផល និងសេវាកម្មរបស់ខេប៊ីប្រាសាក់។

17.10. លោក-លោកស្រី ត្រូវទទួលខុសត្រូវលើការប្រើប្រាស់សេវាខេប៊ីប្រាសាក់ពាណិជ្ជករ។ រាល់ការបាត់បង់ទឹកប្រាក់ក្នុងគណនី ដែលប្រព្រឹត្តដោយចេតនា ឬ អចេតនា ឬ ដោយការធ្វេសប្រហែស ឬ ដោយការសាកល្បងធ្វើប្រតិបត្តិការផ្សេងៗ ការលុកលុយរុករក ការកែបន្លំទិន្នន័យ ការលួចបន្លំដោយផ្ទាល់ ឬ ដោយប្រយោលតែម្នាក់ឯង ឬ ដោយមានការចូលរួមពីអ្នកដទៃ លោក-លោកស្រី ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។

17.11. លោក-លោកស្រី យល់ព្រមដោយឥតលក្ខខណ្ឌក្នុងការទូទាត់សំណងមក ខេប៊ីប្រាសាក់ ករណីមានការប្តឹងតវ៉ា ការទាមទារ ការទទួលខុសត្រូវ ការខាតបង់ ឬ ការចំណាយផ្សេងៗ ដែលខេប៊ីប្រាសាក់ទទួលរងទាក់ទងនឹងប្រតិបត្តិការតាមសេវាខេប៊ីប្រាសាក់ពាណិជ្ជករ ដោយការអនុវត្តបំពានរបស់ លោក-លោកស្រី លើលក្ខខណ្ឌនៃការប្រើប្រាស់សេវាកម្មនេះ រួមទាំងការខកខានមិនបានចាត់វិធានការទប់ស្កាត់ ការធ្វើប្រតិបត្តិការដោយគ្មានការអនុញ្ញាត ឬ ប្រតិបត្តិការក្លែងបន្លំ។ល។

17.12. លោក-លោកស្រី ត្រូវធានាពីការរក្សាសុវត្ថិភាពទូរស័ព្ទ និងព័ត៌មានសម្ងាត់ ដើម្បីចូលប្រើប្រាស់សេវាខេប៊ីប្រាសាក់ពាណិជ្ជករ ដូចជាលេខកូដសម្ងាត់ និងព័ត៌មានផ្ទាល់ខ្លួន។ល។

17.13. លោក-លោកស្រី ត្រូវធានាថាបានដំឡើង ឬ ធ្វើបច្ចុប្បន្នភាព **កម្មវិធីខេប៊ីប្រាសាក់ពាណិជ្ជករ** (KB PRASAC Merchant App) ដោយផ្ទាល់ពី Play Store ឬ App Store និងធានាថាបានប្រើប្រាស់សេវាខេប៊ីប្រាសាក់ពាណិជ្ជករ ជំនាន់ថ្មីបំផុត ដែលបានដាក់ឱ្យប្រើប្រាស់ ឬ ធ្វើបច្ចុប្បន្នភាពពីខេប៊ីប្រាសាក់។

17.14. លោក-លោកស្រី ត្រូវជូនដំណឹងមក ខេប៊ីប្រាសាក់ ជាលាយលក្ខណ៍អក្សរឱ្យបានទាន់ពេលវេលា ក្នុងករណីមានការផ្លាស់ប្តូរលេខទូរស័ព្ទ អ៊ីម៉ែល និង/ឬព័ត៌មានផ្ទាល់ខ្លួនផ្សេងៗ ដែលបានផ្តល់មក ខេប៊ីប្រាសាក់។ រាល់ការខាតបង់ ឬ ការពន្យារពេលផ្សេងៗដែលអាចកើតមកពីការខកខានមិនបានជូនដំណឹងមក ខេប៊ីប្រាសាក់ ជាការទទួលខុសត្រូវទាំងស្រុងរបស់ លោក-លោកស្រី។

17.15. លោក-លោកស្រី មិនត្រូវធ្វើប្រតិបត្តិការណាមួយដែលខុសច្បាប់ ឬ សកម្មភាពអាជីវកម្មណាមួយ ដែលត្រូវបានហាមឃាត់តាមរយៈសេវាខេប៊ីប្រាសាក់ពាណិជ្ជករ ឡើយ។

17.16. លោក-លោកស្រី មានសិទ្ធិក្នុងការផ្ទៀងផ្ទាត់ព័ត៌មាននៅក្នុងរបាយការណ៍គណនីរបស់ខ្លួន និងសាកសួរមក ខេប៊ីប្រាសាក់ ក្នុងករណីមានភាពមិនប្រក្រតីណាមួយកើតឡើង។

17.17. ការគ្រប់គ្រងហាង លោក-លោកស្រី អាចបង្កើតហាងបានច្រើនកន្លែង ដោយអាចបន្ថែម ឬ បិទហាងបានតាមការចាំបាច់។ អនុញ្ញាតឱ្យអ្នកគិតលុយ ចូលប្រើប្រាស់សេវាខេប៊ីប្រាសាក់ពាណិជ្ជករបាន តាមរយៈការណែនាំពីលោក-លោកស្រី នឹងអាចត្រួតពិនិត្យការលក់នៅតាមហាង ឬ បញ្ជរគិតលុយនីមួយៗ។

17.18. ក្នុងករណី លោក-លោកស្រី មានបញ្ហាផ្សេងៗពាក់ព័ន្ធនឹងការប្រើប្រាស់សេវាខេប៊ីប្រាសាក់ពាណិជ្ជករ លោក-លោកស្រី ត្រូវជូនដំណឹងជាបន្ទាន់មក ខេប៊ីប្រាសាក់ តាមរយៈទូរស័ព្ទ 023/086 999 911។

17.19. លោក-លោកស្រី ត្រូវធានាថា រាល់បុគ្គលិកដែលលោក-លោកស្រីបានចាត់តាំងក្នុងការប្រើប្រាស់សេវាខេប៊ីប្រាសាក់ពាណិជ្ជករ ជាបុគ្គលស្របច្បាប់ និងមានសិទ្ធិពេញលេញក្នុងការប្រើប្រាស់សេវាខេប៊ីប្រាសាក់ពាណិជ្ជករ។

17.20. លោក-លោកស្រី ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវគ្រប់ចំណុចនៅលើ **លក្ខខណ្ឌនៃការប្រើប្រាស់សេវាខេប៊ីប្រាសាក់ពាណិជ្ជករ** នេះ។

18. សិទ្ធិ និងកាតព្វកិច្ចរបស់ខេប៊ីប្រាសាក់

18.1. ខេប៊ីប្រាសាក់ មានសិទ្ធិផ្ទៀងផ្ទាត់ព័ត៌មានរបស់ លោក-លោកស្រី និងសម្រេចក្នុងការផ្តល់ជូននូវសេវាពាណិជ្ជករដល់ លោក-លោកស្រី។

18.2. ខេប៊ីប្រាសាក់ នឹងអនុវត្តតាមការបញ្ជាលើប្រតិបត្តិការនៃការទទួលការទូទាត់តាមរយៈសេវាខេប៊ីប្រាសាក់ពាណិជ្ជកររបស់លោក-លោកស្រី ប៉ុន្តែខេប៊ីប្រាសាក់ មិនទទួលខុសត្រូវ ក្នុងករណីដែល លោក-លោកស្រី បានបញ្ចូលព័ត៌មាន ឬ លេខគណនីខុស ឬ កំណត់សមតុល្យលើស ឬ ខ្វះ ជាដើម។

18.3. ខេប៊ីប្រាសាក់ មានសិទ្ធិសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចក្នុងការស៊ើបអង្កេត បង្ខាំង ឬ បញ្ឈប់ការប្រើប្រាស់សេវាខេប៊ីប្រាសាក់ពាណិជ្ជករ របស់ លោក-លោកស្រី ដោយយោងលើច្បាប់/បទបញ្ជត្តិ ឬ ដីកាពីតុលាការ។

18.4. ខេប៊ីប្រាសាក់ នឹងរក្សាការសម្ងាត់នូវរាល់ព័ត៌មានរបស់ លោក-លោកស្រី លើកលែងមានការយល់ព្រមពី លោក-លោកស្រី ឬ ច្បាប់តម្រូវ ឬ មានដីកាពីតុលាការបង្គាប់ឱ្យបង្ហាញព័ត៌មានសម្ងាត់ទាំងនោះ។

18.5. ខេប៊ីប្រាសាក់ រក្សាសិទ្ធិក្នុងការកែប្រែ ឬ អនុវត្តការយកកម្រៃសេវាប្រចាំឆ្នាំ/ប្រចាំខែ និង/ឬ កម្រៃសេវាពាក់ព័ន្ធ លើការប្រើប្រាស់ និង/ឬ ប្រតិបត្តិការតាមរយៈសេវាខេប៊ីប្រាសាក់ពាណិជ្ជករ អាស្រ័យលើលក្ខខណ្ឌ និងស្ថានភាពអាជីវកម្មជាក់ស្តែង។

18.6. ខេប៊ីប្រាសាក់ រក្សាសិទ្ធិក្នុងការធ្វើបច្ចុប្បន្នភាពជាប្រចាំលើសេវាខេប៊ីប្រាសាក់ពាណិជ្ជករ ទៅជំនាន់ថ្មីៗ ដោយ ខេប៊ីប្រាសាក់ អាចនឹង៖

- ដាក់បន្ថែមនូវមុខងារប្រតិបត្តិការថ្មីៗ ដោយយោងទៅតាមនិន្នាការទីផ្សារ និង/ឬ ការប្រែប្រួលបច្ចេកវិទ្យា ឬ
- លុប ឬ ផ្អាកជាបណ្តោះអាសន្នលើមុខងារណាមួយ ប្រសិនបើមានបញ្ហាបច្ចេកទេសណាមួយកើតឡើង ដែលអាចមានផលប៉ះពាល់ដល់ប្រព័ន្ធធនាគារ ឬ ក្នុងគោលបំណងថែទាំប្រព័ន្ធ ឬ ផ្សេងៗ។

18.7. នៅក្នុងដំណាក់កាលណាមួយ ខេប៊ីប្រាសាក់ អាចនឹងជំរុញឱ្យ លោក-លោកស្រី ធ្វើបច្ចុប្បន្នភាពសេវាខេប៊ីប្រាសាក់ពាណិជ្ជករ មកជំនាន់ថ្មីចុងក្រោយបង្អស់ (Update Last Version) ដើម្បីបង្កើនសុវត្ថិភាព និងភាពដូចគ្នាលើការប្រើប្រាស់សេវាខេប៊ីប្រាសាក់ពាណិជ្ជករ។

18.8. ប្រសិនបើ សេវាខេប៊ីប្រាសាក់ពាណិជ្ជករ របស់លោក-លោកស្រី មិនអាចប្រើប្រាស់បានដោយករណីប្រធានសក្តិ ខេប៊ីប្រាសាក់ នឹងជួយដល់ លោក-លោកស្រី ក្នុងការរកដំណោះស្រាយ ឬ ផ្តល់ជំនួយការចាំបាច់ណាមួយយោងលើហេតុផលជាក់ស្តែង ប៉ុន្តែខេប៊ីប្រាសាក់មិនទទួលខុសត្រូវទៅលើហេតុការណ៍ទាំងនោះទេ។

18.9. ខេប៊ីប្រាសាក់រក្សាសិទ្ធិក្នុងការផ្អាកប្រតិបត្តិការពេលមានបញ្ហាផ្សេងៗ និងពេលមានការចាំបាច់ជាដើម។

18.10. ខេប៊ីប្រាសាក់ ផ្តល់លេខទូរស័ព្ទសម្រាប់បម្រើសេវាប្រឹក្សាអំពីសេវាកម្ម និងការរាយការណ៍ពីការភ្លេចលេខសម្ងាត់ ឬ បញ្ហាផ្សេងៗដែលកើតមាន តាមរយៈលេខ 023/086 999 911។

19. ការកែប្រែកម្រៃសេវា ទំហំកំណត់ លក្ខខណ្ឌផ្សេងៗ និងការជូនដំណឹង

19.1. ខេប៊ីប្រាសាក់ រក្សាសិទ្ធិក្នុងការកែប្រែកម្រៃសេវា ទំហំកំណត់ និង/ឬ លក្ខខណ្ឌផ្សេងៗដែលត្រូវអនុវត្តចំពោះការប្រើប្រាស់សេវាខេប៊ីប្រាសាក់ពាណិជ្ជករ របស់ លោក-លោកស្រី ដោយ ខេប៊ីប្រាសាក់ នឹងធ្វើការជូនដំណឹងទៅអតិថិជនឱ្យបានត្រឹមត្រូវតាមលក្ខខណ្ឌតម្រូវនៃច្បាប់។

19.2. ក្នុងរយៈពេលនៃការជូនដំណឹងខាងលើ ករណីមិនមានការតវ៉ាពី លោក-លោកស្រី ត្រូវសន្មតថា លោក-លោកស្រីបានយល់ព្រម និងទទួលយកការកែប្រែទាំងនោះមកអនុវត្តភ្លាមៗបន្ទាប់ពីការកែប្រែចូលជាធរមានដែលត្រូវបានផ្សព្វផ្សាយតាមរយៈមធ្យោបាយណាមួយខាងក្រោម៖

ក) សាខាខេប៊ីប្រាសាក់ និង/ឬ

ខ) វេបសាយត៍ និង/ឬ បណ្តាញទំនាក់ទំនងសង្គមផ្លូវការរបស់ ខេប៊ីប្រាសាក់ និង/ឬ

គ) ការផ្ញើសារ និង/ឬ អ៊ីម៉ែលទៅកាន់ លោក-លោកស្រី

ឃ) ការផ្សព្វផ្សាយនៅលើទំព័រការសែត ទស្សនាវដ្តី សេវាខេប៊ីប្រាសាក់ពាណិជ្ជករ ឬ មធ្យោបាយផ្សេងៗដែលខេប៊ីប្រាសាក់ បានជ្រើសរើស។ល។

19.3. អតិថិជនត្រូវបានសន្មតថាបានទទួលការជូនដំណឹងស្តីពីការកែប្រែខាងលើភ្លាមៗ បន្ទាប់ពីខេប៊ីប្រាសាក់បានធ្វើការចុះផ្សាយពីការកែប្រែព័ត៌មាននានារបស់ខ្លួនតាមរយៈមធ្យោបាយណាមួយក្នុងចំណោមមធ្យោបាយខាងលើ។

20. ការទប់ស្កាត់ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

អនុលោមតាមបទប្បញ្ញត្តិទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ខេប៊ីប្រាសាក់ អាចនឹងពន្យារពេល ឬ មិនធ្វើប្រតិបត្តិការជូន លោក-លោកស្រី បាន ប្រសិនបើ ខេប៊ីប្រាសាក់មានការជឿជាក់ដោយផ្អែកលើមូលហេតុដូចខាងក្រោម៖

ក) ខេប៊ីប្រាសាក់ មានការសង្ស័យចំពោះប្រភពដើមនៃប្រាក់នោះ

ខ) ប្រតិបត្តិការ ឬ គណនីនោះមានទំនាក់ទំនង ឬ ពាក់ព័ន្ធដោយផ្ទាល់ ឬ ដោយប្រយោលជាមួយនឹងសកម្មភាពល្មើសច្បាប់ណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា ឬ ច្បាប់អន្តរជាតិ

គ) មានការបង្គាប់បញ្ជាពីតុលាការ ឬ ធនាគារជាតិ នៃ កម្ពុជា។ល។

21. ច្បាប់ និងការដោះស្រាយវិវាទ

21.1. លក្ខខណ្ឌប្រើប្រាស់នេះ ត្រូវបានគ្រប់គ្រង និងបកស្រាយដោយយោងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

21.2. ករណីមានវិវាទកើតឡើង ភាគីទាំងពីរត្រូវដោះស្រាយដោយសន្តិវិធី។ ករណីវិវាទមិនអាចដោះស្រាយបានដោយសន្តិវិធី ឬ ក្រៅប្រព័ន្ធតុលាការ នោះវិវាទត្រូវដោះស្រាយទៅតាមប្រព័ន្ធតុលាការដោយយោងទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

21.3. លក្ខខណ្ឌផ្សេងៗដែលមិនមានចែងនៅក្នុង «**លក្ខខណ្ឌប្រើប្រាស់**» នេះ ត្រូវអនុវត្តតាមគោលការណ៍របស់ខេប៊ីប្រាសាក់ និង/ឬ ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

22. ស្វ័យភាព នៃបញ្ញត្តិ

ប្រសិនបើប្រការណាមួយនៃលក្ខខណ្ឌប្រើប្រាស់នេះ មិនអាចអនុវត្តបាន ឬ គ្មានសុពលភាពតាមផ្លូវច្បាប់ ប្រការទាំងនោះនឹងអស់សុពលភាពត្រឹមកម្រិតដែលប្រការនោះមិនអាចអនុវត្តបាន ឬ អសុពលភាពនៃប្រការនោះតែប៉ុណ្ណោះ ចំណែកប្រការផ្សេងៗទៀតនៃលក្ខខណ្ឌប្រើប្រាស់នេះនៅតែបន្តមានសុពលភាពអនុវត្តដដែល។

23. ភាសា

លក្ខខណ្ឌប្រើប្រាស់នេះ ត្រូវបានធ្វើឡើងជាភាសាខ្មែរ និងអង់គ្លេស។ ករណីមានចំណុចណាមួយរវាងអត្ថបទទាំងពីរមានន័យមិនស្រប ឬ មិនស៊ីគ្នា នោះអត្ថបទជាភាសាខ្មែរចាត់ទុកជាផ្លូវការ៕